# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីពុទ្ធភាសិតមួយបទពោលថា ត្រូវយកខ្លួនជាទីពឹង
## យកធម៌ជាតីពឹង អ្វីក្រៅពីនោះពុំមែនជាទីពឹងឡើយ

**Web site: hoksavann.org**

ថ្ងៃទី១៧ កញ្ញា ២០០៥

ពុទ្ធភាសិតមួយបទពោលថា អត្តទីបា ភិក្ខវេ ធម្មទីបា វិហរថ អនញ្ញសរណា ប្រែថាម្នាលភិក្ខុទាំងឡាយ ចូរអ្នកយកខ្លួនជាទីពឹង និងយកធម៌ជាទីពឹង អ្វីដទៃក្រៅពីខ្លួនអ្នកនិងធម៌ ពុំមែនជាទីពឹងរបស់អ្នកឡើយ ។

ពាក្យថា យកខ្លួនជាទីពឹង បានសេចក្តីថា សកម្មភាពល្អគ្រប់យ៉ាង ត្រូវកើតចេញមកពីខ្លួនឯង អ្នកដទៃពុំអាចធ្វើសេចក្តីល្អជំនួសខ្លួនបានឡើយ ។ ស្របនឹងភាសិតពោលថា សេចក្តីបរិសុទ្ធនិងមិនបរិសុទ្ធកើតចេញមកពីខ្លួនឯង អ្នកដទៃពុំអាចញុំាងអ្នកដទៃឲ្យបរិសុទ្ធនិងមិនបរិសុទ្ធបានឡើយ ។ ព្រះអរហន្តទាំងឡាយ មានព្រះពុទ្ធជាដើម ដែលបានសំរេចធម៌ជាន់ខ្ពស់ ពោលគឺព្រះនិព្វានជាទីលត់ទុក្ខ ដោយសារលោកប្រតិបត្តិដោយខ្លួនឯង ។ កុំថាឡើយអ្នកដទៃ សូម្បីឪពុកម្តាយកូនចៅប្តីប្រពន្ធ ក៏ពុំបានធ្វើសេចក្តីល្អឲ្យដល់គ្នា ឬជួសគ្នាបានឡើយ ។

ពាក្យថា យកធម៌ជាទីពឹងបានសេចក្តីថា យកពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធមកអនុវត្តតាម គឺព្រះអង្គបានបង្ហាញនូវព្រះធម៌ដែលជាមាគ៌ានាំមនុស្សសត្វទៅរកសេចក្តីសុខក្សេមក្សាន្តក្នុងសង្គមមនុស្ស និងសុខជាន់ខ្ពស់នៃព្រះនិព្វាន ។

មាគ៌ានៃព្រះធម៌គឺ ទានសីលភាវនាសំរាប់គ្រហស្ថប្រតិបត្តិ និងសិលសមាធិបញ្ញាសំរាប់បុព្វជិតប្រតិបត្តិ ។ បានសេចក្តីថា ពុទ្ធបរិស័ទយកខ្លួនជាទីពឹង គឺប្រតិបត្តិដោយខ្លួនឯងហើយតើប្របត្តិតាមផ្លូវណា គឺប្រតិបត្តិតាមព្រះធម៌ គឺមគ្គប្រកបដោយអង្គ៨ គឺជាមាគ៌ាចេញចាកទុក្ខ ដែលព្រះពុទ្ធបានសំដែង ។ ព្រះពុទ្ធដូចជាអ្នកបញ្ចេញផ្លូវគថែម៌ ឯមនុស្សសត្វត្រូវដើរ គឺប្រតិបត្តិតាមព្រះធម៌ដោយខ្លួនឯង ។ ប្រៀបដូចអ្នកស្គាល់ផ្លូវ ប្រាប់អ្នកវង្វេងផ្លូវ ត្រូវអ្នកវង្វេងផ្លូវដើរដោយខ្លួនឯង ពុំអាចឲ្យអ្នកស្គាល់ផ្លូវដើរជួសអ្នកវង្វេងផ្លូវបានឡើយ ក៏មានន័យដូចខាងលើនេះដែរ ។

ពាក្យថា ក្រៅពីខ្លួនឯងនិងក្រៅពីព្រះធម៌ពុំមែនទីពឹង បានសេចក្ដីថា សេចក្ដីសុខចំរើនគ្រប់យ៉ាងកើតអំពីអំពើល្អរបស់ខ្លួន ដូចពុទ្ធភាសិតថា សត្វទាំងឡាយមានកម្មជារបស់ខ្លួន (កម្មស្សកោម្ហិ) ឯអ្នកដែលអាចប្រព្រឹត្តល្អបាន ដល់ការស្ដាប់ព្រះធម៌ហ្នឹងឯង ។ ដូច្នេះក្នុងន័យនេះបញ្ជាក់ថា ទេវតាព្រះឥន្ទព្រះព្រហ្មព្រះអាទិទេពពុំអាចជួយខ្លួនឲ្យបានសុខឡើយ នេះជាទ្រឹស្ដីកម្មផលរបស់ព្រះពុទ្ធសាសនា ។៚

9 9

9